ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យអង្គរ
លេខ .............................ស.អ.

# កំណើន និងការថែរក្សាប្រកបដោយភាពទទួលខុសត្រូវ

## ផែនការប្រតិបត្តិសម្រាប់ឆ្នាំសិក្សា ២០២០-២០២១

ខែ ធ្នូ ឆ្នាំ ២០២០

# កំណើន និងការថែរក្សាប្រកបដោយភាពទទួលខុសត្រូវ

## ផែនការប្រតិបត្តិសម្រាប់ឆ្នាំសិក្សា ២០២០-២០២១

**ខែ ធ្នូ ឆ្នាំ ២០២០**

## មាតិកា

**ទំព័រ**


មាតិកា......i.
អារម្ភកថា......vi.
បញ្ជីតារាង......viii.
**លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមឆ្នាំ២០១៩-២០២០......ix.**
**ជំពូក ១......១**
**សេចក្តីផ្តើម......១**
**ជំពូក ២......៥**
**ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តន័យឡូហ្គោ......៥**
១.១. ចក្ខុវិស័យ......៥
១.២. បេសកកម្ម......៥
១.៣. តម្លៃស្នូល......៥
១.៤. អត្តន័យឡូហ្គោ......៦
**ជំពូក ៣......៧**
**គោលដៅយុទ្ធសាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ......៧**
៣.១. គោលដៅយុទ្ធសាស្ត្រ......៧
៣.២. ទិសដៅយុទ្ធសាស្ត្រ......៧
**ជំពូក ៤......១៣**
**លទ្ធផលរំពឹងទុក និងសកម្មភាពចម្បង......១៣**
៤.១. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់......១៣
៤.១.១- អភិវឌ្ឍរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ ការិយាល័យ និងអង្គភាពចំណុះ......១៣
៤.១.២- កែសម្រួលបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាភិបាល......១៣
៤.១.៣- បន្សុីលទ្ធផលអនុវត្តការងារជាមួយចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តន័យរបស់ឡូហ្គោដែលបានកំណត់......១៤
៤.២. ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត......១៤
៤.២.១- ធ្វើសង្គតិភាពគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍បុគ្គលិករដ្ឋបាលទៅនឹងតួនាទីភារកិច្ចរបស់ខ្លួន......១៤
៤.៣. ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់......១៥

៤.៣.១- កែលម្អគោលការណ៍លើកទឹកចិត្តបុគ្គលិក ............................................................ ១៥
៤.៣.២- រៀបចំផែនការប្រចាំខែ និងត្រីមាស .................................................................. ១៥
៤.៣.៣- រៀបចំរបាយការណ៍ប្រចាំខែ និងត្រីមាស ............................................................ ១៥
**៤.៤. ការកំណត់ប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់**........................................................ ១៦
៤.៤.១- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អបុគ្គលិកគ្រប់ជាន់ថ្នាក់ ប្រចាំត្រីមាស............. ១៦
៤.៤.២- វាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅប្រចាំខែ ត្រីមាស និងឆ្នាំ ........................ ១៦
**៤.៥. ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព** ...................................................... ១៦
៤.៥.១- រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ................................................ ១៦
៤.៥.២- ធ្វើសង្គតិភាពប្រព័ន្ធគណនេយ្យ ស.អ. ទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា...... ១៧
៤.៥.៣- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ........................................ ១៧
៤.៥.៤- ធ្វើសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ស្របតាមគោលការណ៍គណនេយ្យ ស.អ. .......................... ១៧
**៤.៦. ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ** ........................................................... ១៨
៤.៦.១- កែសម្រួលកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់
ឧត្តមសិក្សា ........................................................................................ ១៨
៤.៦.២- កែសម្រួលកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះបណ្តាល ........ ១៨
៤.៦.៣- ចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត.............................. ១៨
៤.៦.៤- ស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល ........................ ១៩
៤.៦.៥- អភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល ............................... ១៩
៤.៦.៦- ស្រាវជ្រាវសៀវភៅយោងបន្ថែម តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល .................. ២០
៤.៦.៧- ស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាល.................................... ២០
**៤.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ** ...................................................... ២០
៤.៧.១- ពិនិត្យ និងកែលម្អបទបញ្ជាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យ ........................................ ២០
៤.៧.២.-ធ្វើការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ. .......................... ២១
៤.៧.៣-លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ.................................................................. ២១
៤.៧.៤- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន ............................................................ ២១
**៤.៨.ការអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ** ........................................ ២២
៤.៨.១- ពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និង
ការស្រាវជ្រាវ ...................................................................................... ២២
៤.៨.២- ពិនិត្យ វាយតម្លៃ និងអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវ ............ ២២
៤.៨.៣- បង្កើននិងអភិវឌ្ឍសំណង់អគារព្រមទាំងសម្ភាររូបវន្តសម្រាប់ការសិក្សា និង

ស្រាវជ្រាវ ..........២៣
**៤.៩. ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ** ..........២៣
៤.៩.១- ផ្សព្វផ្សាយ និងតម្រង់ទិសអំពីបទបញ្ញាផ្ទៃក្នុងនិស្សិត ..........២៣
៤.៩.២- រៀបចំសន្និសីទ សិក្ខាសាលា និងបាឋកថា ..........២៣
៤.៩.៣- ជំរុញនិស្សិតចូលរួមកម្មវិធីសហគមន៍ ធ្វើកម្មសិក្សា និងសកម្មភាពសង្គមផ្សេងៗ ..........២៤
**៤.១០. ការបង្កើនគុណភាពផ្តល់សេវាកម្មនិស្សិត** ..........២៤
៤.១០.១- ប្រឹក្សានិស្សិត គ្រប់កម្រិត ..........២៤
៤.១០.២- ពង្រឹងវិន័យ និងក្រមសីលធម៌និស្សិតគ្រប់កម្រិត..........២៥
៤.១០.៣-លើកទឹកចិត្តនិស្សិតគ្រប់កម្រិត ..........២៥
៤.១០.៤- កែសម្រួលក្លឹបនិស្សិតស្ម័គ្រចិត្ត អតីតនិស្សិត និងក្លឹបផ្សេងៗ ..........២៥
៤.១០.៥- រៀបចំកម្មវិធី ព្រឹត្តិការណ៍ ទស្សនកិច្ចសិក្សា ..........២៦
៤.១០.៦- រៀបចំស្ទង់មតិអំពីភាពមានការងារធ្វើរបស់និស្សិត និងអតីតនិស្សិត..........២៦
**៤.១១. ការរៀបចំការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ**..........២៧
៤.១១.១- កែលម្អគោលការណ៍ និងនីតិវិធីស្រាវជ្រាវរបស់ ស.អ. ..........២៧
៤.១១.២- ទាក់ទាញគម្រោងស្រាវជ្រាវពីស្ថាប័ននានា ..........២៧
៤.១១.៣- ពិនិត្យ និងកែសម្រួលលក្ខន្តិកៈមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីឧត្តមភាព
និងនវានុវត្តន៍ ..........២៧
**៤.១២. ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណាននិស្សិត**..........២៨
៤.១២.១-បង្កើតកម្មវិធីប្រកួតប្រជែង ..........២៨
**៤.១៣. ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ** ..........២៨
៤.១៣.១-លើកទឹកចិត្តបុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យឱ្យស្រាវជ្រាវ..........២៨
៤.១៣.២.-ផ្សព្វផ្សាយស្នាដៃរបស់អ្នកស្រាវជ្រាវ ..........២៨
**៤.១៤. ការធ្វើទំនើបកម្ម និងនវានុវត្តឯកសារសម្រាប់ស្រាវជ្រាវ** ..........២៩
៤.១៤.១-ពិនិត្យ និងកែលម្អគោលការណ៍ស្តីពីការបណ្តុះបណ្តាលពីចម្ងាយ និងតាមប្រព័ន្ធ
អេឡិចត្រូនិក ..........២៩
៤.១៤.២- ពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់បណ្ណាល័យទូរនិម្មិត ..........២៩
៤.១៤.៣-បំប្លែងឯកសារទៅជាឌីជីថល..........២៩
**៤.១៥. ការបោះពុម្ព និងផ្សព្វផ្សាយ** ..........៣០
៤.១៥.១- ចងក្រងឯកសារនានា របស់ ស.អ. ..........៣០
៤.១៥.២- បោះពុម្ព និងផ្សព្វផ្សាយឯកសារនានា របស់ ស.អ. ..........៣០

**៤.១៦. ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ ......................................... ៣១**
៤.១៦.១- បន្តអនុវត្ត និងធ្វើអនុស្សរណៈយោគយល់គ្នាជាមួយដៃគូជាតិ និងអន្តរជាតិថ្មីបន្ថែម ...... ៣១
**៤.១៧. ការផ្លាស់ប្តូរវប្បធម៌ ......................................... ៣១**
៤.១៧.១-ជំរុញបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតគ្រប់កម្រិតធ្វើទស្សនកិច្ចសិក្សា ចូលរួម វេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា នៅក្នុងប្រទេស និងបរទេស ....... ៣១
៤.១៧.២-ទទួលបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតគ្រប់កម្រិតពីដៃគូជាតិ និងអន្តរជាតិ ធ្វើទស្សន-កិច្ចសិក្សា ចូលរួមវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានានៅ ស.អ............ ៣២
**៤.១៨. ការផ្តល់អាហារូបករណ៍ ......................................... ៣៣**
៤.១៨.១- កែលម្អគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍ ......................................... ៣៣
៤.១៨.២-ស្វែងរកមូលនិធិសម្រាប់គាំទ្រដល់ការផ្តល់អាហារូបករណ៍ ......................................... ៣៣
**៤.១៩. ការស្រាវជ្រាវរួមគ្នា ......................................... ៣៣**
៤.១៩.១- ពិនិត្យ និងកែលម្អគោលការណ៍ស្រាវជ្រាវរួមគ្នា ......................................... ៣៣
៤.១៩.២-ស្វែងរកមូលនិធិសម្រាប់គាំទ្រដល់ការស្រាវជ្រាវ ......................................... ៣៤
៤.១៩.៣-បោះពុម្ពគម្រោងស្រាវជ្រាវរួមគ្នា ......................................... ៣៤
**៤.២០. ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ......................................... ៣៤**
៤.២០.១- ពិនិត្យ និងកែសម្រួលគោលការណ៍ធានាគុណភាពអប់រំផ្ទៃក្នុងរបស់ ស.អ. ......................................... ៣៤
**៤.២១. ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង ......................................... ៣៤**
៤.២១.១-អនុវត្ត តាមដាន និងវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង ......................................... ៣៤
៤.២១.២-រៀបចំនិទ្ទេសបទស្វ័យវាយតម្លៃ ......................................... ៣៥
**៤.២២. ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ/អន្តរជាតិ ......................................... ៣៥**
៤.២២.១-បន្តអនុវត្តស្តង់ដារបស់ គ.ទ.ក ដើម្បីត្រៀមខ្លួនវាយតម្លៃ ......................................... ៣៥
៤.២២.២-រៀបចំគោលការណ៍នានាដើម្បីត្រៀមខ្លួនវាយតម្លៃគុណភាពអប់រំស្របតាមស្តង់ដា ISO ......................................... ៣៥
**ជំពូក ៥ ......................................... ៣៧**
**ផែនការសកម្មភាព ......................................... ៣៧**
**ជំពូក ៦ ......................................... ៥៩**
**ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០២០-២០២១ ......................................... ៥៩**
**ជំពូក ៧ ......................................... ៦២**
**ការពិនិត្យ តាមដាន និងវាយតម្លៃ ......................................... ៦២**
៧.១. ការកំណត់ក្រុមការងារ ......................................... ៦២

៧.២. រៀបចំកាលបរិច្ឆេទលម្អិតសម្រាប់ការបង្កើតផែនការប្រតិបត្តិ ........................................... ៦២
៧.៣. រៀបចំហិរញ្ញវត្ថុសម្រាប់ការរៀបចំផែនការប្រតិបត្តិ ........................................... ៦៣
៧.៤. កំណត់នីតិវិធីតាមដាន និងការអនុវត្តផែនការរៀបចំ ........................................... ៦៣
**ជំពូក ៨** ........................................... **៦៤**
**កត្តាប្រឈម និងសេចក្តីសន្និដ្ឋាន** ........................................... **៦៤**

# អារម្ភកថា

ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០-២០២១ នេះត្រូវបានបង្កើត និងចងក្រងដោយថ្នាក់ដឹកនាំរបស់សាកលវិទ្យាល័យអង្គរ (ស.អ.) ដែលទាញចេញពីផែនការយុទ្ធសាស្ត្រ ២០១៨-២០២៣«វិថីអេយូទំនោរជោគជ័យ» ស្របតាមគោលដៅដូចជា ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ ការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ។

ផែនការប្រតិបត្តិនេះ រចនាឡើងក្នុងបរិបទដែល ស.អ. បានបិទបញ្ចប់ស្ថានភាពស្តារ ហើយចាប់ផ្តើមពង្រឹង និងពង្រីកការផ្តល់សេវាកម្មអប់រំ ជាពិសេសកំពុងបង្កើនកិត្យានុភាពក្នុងក្របខណ្ឌការប្រកួតប្រជែងប្រកបដោយភាពទំនួលខុសត្រូវ និងស្ថានភាពប្រឈមនៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩។ ដូចនេះ ផែនការប្រតិបត្តិត្រូវបានផ្តល់ឈ្មោះថា «កំណើន និងការថែរក្សាប្រកបដោយភាពទទួលខុសត្រូវ» ។

«កំណើន និងការថែរក្សាប្រកបដោយភាពទទួលខុសត្រូវ» ត្រូវបានចែកចេញជា ៨ ជំពូក ដែលជំពូក ១ រៀបរាប់អំពីអាសយដ្ឋាន លិខិតូបករណ៍ផ្លូវការ អាជ្ញាបណ្ណអនុញ្ញាត និងមុខជំនាញដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជននិងកីឡា និង ក្រសួងសុខាភិបាល។ នៅត្រង់ជំពូក ២ មានការពន្យល់អំពីចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តន័យឡូហ្គោ។ ក្រៅពីនេះ ជំពូក ៣ បង្ហាញអំពីគោលដៅយុទ្ធសាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ សម្រាប់ការបន្តរៀបចំ និងអភិវឌ្ឍ ស.អ. ស្របតាមបរិបទប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូវីដ-១៩។ ជំពូក ៤ ត្រូវបានរំលេចអំពីលទ្ធផលរំពឹងទុក និងសកម្មភាពការងារលម្អិតសម្រាប់បង្កើនភាពងាយស្រួលក្នុងការអនុវត្តរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់។ សម្រាប់ជំពូក ៥ ត្រូវបានសង្កត់ធ្ងន់លើសកម្មភាពលម្អិតដែលកំណត់អំពីសកម្មភាពចម្បង កាលបរិច្ឆេទ និងអ្នកទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងមានបង្ហាញនូវប្រភពចំណាយ ដែលទាញចេញពីគណនី និងអនុគណនី។ ចំណែកឯ ជំពូក ៦ បានបង្ហាញអំពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងយ៉ាងច្បាស់លាស់ ដើម្បីធ្វើឱ្យការងារមានប្រសិទ្ធភាពខ្ពស់។ ក្រៅពីនេះ ជំពូក ៧ បានសង្កត់ធ្ងន់លើការពិនិត្យ តាមដាន និងវាយតម្លៃលើផែនការប្រតិបត្តិប្រចាំឆ្នាំនេះ។ ជាចុងក្រោយ ជំពូក ៨ បានធ្វើការសន្និដ្ឋានលើផែនការដែលមានឈ្មោះថា កំណើន និងការថែរក្សាប្រកបដោយភាពទទួលខុសត្រូវ។

ផែនការនេះ ជាមូលដ្ឋានដ៏រឹងមាំ និងជាផែនទីដ៏ច្បាស់លាស់ដើម្បីចង្អុលបង្ហាញនិងតម្រង់ទិសដល់ក្រុមការងារ ជាពិសេសថ្នាក់ដឹកនាំក្នុងការគ្រប់គ្រង តាមដាន វាយតម្លៃប្រកបដោយស្មារតីទទួលខុសត្រូវ និងនិរន្តរភាពរបស់អង្គភាព។

ក្នុងនាមជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យអង្គរ និងជាប្រធានក្រុមការងារដឹកនាំការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០-២០២១ សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់សមាជិក សមាជិកា របស់ក្រុមការងារសម្របសម្រួល ក្រុមការងារបច្ចេកទេសឱហ្សាញនិងរចនា និងក្រុមការងារបច្ចេកទេសនិងត្រួតពិនិត្យអក្ខរាវិរុទ្ធ ព្រមទាំងក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការរង សមាជិក/សមាជិកាក្រុមប្រឹក្សាអប់រំនិងបណ្តុះបណ្តាល

ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រឹទ្ធបុរស/ព្រឹទ្ធបុរសរង ប្រធាន/អនុប្រធានការិយាល័យ អង្គភាពចំណុះ គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតដែលបានចូលរួមចំណែកក្នុងការកសាងនូវផែនការប្រតិបត្តិតាមរយៈយោបល់ ទស្សនាទាន និងគំនិតនានា ប្រកបដោយស្មារតីយោគយល់ និងចក្ខុវិស័យវែងឆ្ងាយ។

ជាចុងក្រោយខ្ញុំសូមជូនពរដល់ក្រុមការងារទាំងអស់ដែលបានរៀបរាប់ខាងលើឱ្យជួបនូវ ពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ............................ខែ......... ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ក្រុងសៀមរាប ថ្ងៃទី..........ខែ.............ឆ្នាំ ២០២០

**សកលវិទ្យាធិការ**

# បញ្ជីតារាង

**ទំព័រ**


តារាងទី០១ ៖ និន្នាការនៃចំនួនបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និស្សិត និងដៃគូអភិវឌ្ឍន៍ .................... ix.

តារាងទី០២ ៖ មុខជំនាញ និងកម្រិតបណ្តុះបណ្តាលតាមមហាវិទ្យាល័យ .......................................... ២

តារាងទី០៣ ៖ សកម្មភាពការងារ និងភាពទំនួលខុសត្រូវ ................................................................ ៣៧

តារាងទី០៤ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២០-២០២១ ...................................................... ៥៩

តារាងទី០៥ ៖ សកម្មភាពតាមដាន ត្រួតពិនិត្យ និងទំនួលខុសត្រូវ ................................................... ៦២

តារាងទី០៦ ៖ រយៈពេលសម្រាប់រៀបចំ និងអនុម័តផែនការប្រតិបត្តិ .................................................. ៦២

តារាងទី០៧ ៖ ហិរញ្ញវត្ថុសម្រាប់ការរៀបចំផែនការ ........................................................................ ៦៣

តារាងទី០៨ ៖ នីតិវិធីតាមដាន និងការអនុវត្តផែនការរៀបចំ .............................................................. ៦៣

## លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមឆ្នាំ២០១៩-២០២០

ស.អ. មានបណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់នៅលើមុខជំនាញជាច្រើន ដែលមាននិស្សិតកំពុងសិក្សាចំនួន ៣០៥នាក់ ក្នុងនោះមហាវិទ្យាល័យសុខភាពសាធារណៈ(ម.ស.ស)ចំនួន ១២៣នាក់ មហាវិទ្យាល័យវិស្វកម្មនិងស្ថាបត្យកម្ម(ម.វ.ស)ចំនួន ៤៧នាក់ មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍(ម.គ.ព.ទ)ចំនួន ៣០នាក់ មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(ម.វ.ប)ចំនួន ០៨នាក់ មហាវិទ្យាល័យមនុស្សសាស្ត្រនិងភាសាបរទេស(ម.ម.ភ)ចំនួន ០៧នាក់ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន(ឆ.ម)ចំនួន ៧៧នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់មុខជំនាញគ្រប់គ្រងពាណិជ្ជកម្មចំនួន ១៣នាក់។

សម្រាប់រយៈពេល ៣ឆ្នាំចុងក្រោយ ស.អ. បានអភិវឌ្ឍ និងបន្តកំណើនប្រកបដោយទំនុកចិត្តខ្ពស់ ជាក់ស្តែងសម្រាប់ឆ្នាំ២០១៩-២០២០ មាននិន្នាការដូចតទៅ៖ បុគ្គលិកកើនឡើងចំនួន ៤៣% សាស្ត្រាចារ្យចំនួន ៩៥% និស្សិតចំនួន ៤០% និងក្រៅពីនេះ ដៃគូអភិវឌ្ឍន៍មានចំនួន ៥៤០% ។

**តារាងទី០១៖ និន្នាការនៃចំនួនបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និស្សិត និងដៃគូអភិវឌ្ឍន៍**

| | ចំនួន(នាក់) | | | ផលធៀប(ភាគរយ) | | |
|---|---|---|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ | ២០១៧ | ២០១៨ | ២០១៩ |
| បុគ្គលិក | ១៨ | ២៣ | ៣៣ | - | ២៨ | ៤៣ |
| សាស្ត្រាចារ្យ | ៣៨ | ៨២ | ១៦០ | - | ១១៦ | ៩៥ |
| និស្សិត | ១៥៥ | ២១៧ | ៣០៥ | - | ៤០ | ៤០ |
| ដៃគូអភិវឌ្ឍន៍ | ៥ | ៥ | ៣២ | - | - | ៥៤០ |

ទោះបីជាលទ្ធផលនៃការអនុវត្តការងារក្នុងឆ្នាំសិក្សាកន្លងទៅមានភាពជោគជ័យមួយកម្រិតក៏ដោយ ក៏ ស.អ. បានជួបនូវបញ្ហាប្រឈមដូចតទៅ៖

- ភាពខ្វះខាតភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់
- ការចូលរួម និងអភិវឌ្ឍពីភាគី គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតនៅមានកម្រិត
- ការលើកទឹកចិត្ត និងវិធានរដ្ឋបាលត្រូវបានអនុវត្តតិចតួច
- កិត្យានុភាព និងកេរ្តិ៍ឈ្មោះនៅមានកម្រិតក្នុងក្រសែភ្នែកអ្នកសិក្សាស្រាវជ្រាវ ព្រមទាំងសាធារណជន និង
- ស្តង់ដា និងការវាយតម្លៃត្រូវបានអនុវត្តមានកម្រិត ក្រោមហេតុផលហិរញ្ញវត្ថុ។

# ជំពូក ១
# សេចក្តីផ្តើម

សាកលវិទ្យាល័យអង្គរ(ស.អ.) ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលត្រូវបានបង្កើតឡើងដោយ អនុក្រឹត្យលេខ ២៣ អនក្រ. បក. ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ ។ អាសយដ្ឋាន ស.អ. កូដប្រៃសណីយ៍ ៖ ១៧២៥៦ ផ្លូវបុរីសៀងណាំ ភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប មានលេខទូរស័ព្ទ៖០៧៨ ៣៨៨ ៨៨២/០៧០ ៨៥ ៣៥ ៣៧ អ៊ីមែល៖ rector@angkor.edu.kh/info@angkor.edu.kh វេបសាយ៖ angkor.edu.kh និងតេឡេក្រាមផ្លូវការ https://t.me/angkoruniversiti ហើយមានការទទួលស្គាល់ដោយ ក្រសួងអប់រំយុវជននិងកីឡា (អយក.)និង ក្រសួងសុខាភិបាល(សខល)។ ក្រៅពីនេះ ស.អ. ក៏បានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម (ពណ) និងមានអត្តលេខបង់ពន្ធត្រឹមត្រូវ ដូចមានបង្ហាញខាងក្រោម៖

- អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការទទួលស្គាល់ ស.អ.
- ប្រកាសលេខ ១០៤៦ អយក.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦ របស់ អយក. ស្តីពីការទទួលស្គាល់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅ ស.អ.
- ប្រកាសលេខ ២៦៥៦ អយក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ របស់ អយក. ស្តីពីការទទួលស្គាល់មុខជំនាញថ្មីនៅ ស.អ. លើមុខជំនាញគ្រប់គ្រងពាណិជ្ជកម្មបង្រៀនជាភាសាអង់គ្លេសនិងកូរ៉េ មុខជំនាញភាសាកូរ៉េ មុខជំនាញគិលានុបដ្ឋាក (កម្រិតបរិញ្ញាបត្ររង) និងមុខជំនាញគិលានុបដ្ឋាក (កម្រិតបរិញ្ញាបត្ររង)
- ប្រកាសលេខ ៣៦២៥ អយក.ឧស. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យសុខភាពសាធារណៈ នៅ ស.អ.
- លិខិត លេខ ១៧៩៨ អយក.ឧស. ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សង្គមសាស្ត្រនិងនីតិសាស្ត្រ កសិកម្ម និងមុខជំនាញភាសាអង់គ្លេសនៅ ស.អ.
- ប្រកាសលេខ ១៧៦៧ អយក.ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្មនៅ ស.អ.
- វិញ្ញាបនបត្របញ្ជាក់ លេខ MOC- ៦៥៩៧៦៤១៦ ពណ.ចបព ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ ពណ ស្តីពីការចុះឈ្មោះបញ្ជីពាណិជ្ជកម្មរបស់ ស.អ.
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារលេខ VATM២០២០០៤១១២៦៨៦ អពដ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ស្តីពីអាករលើតម្លៃបន្ថែម-អតបរបស់ ស.អ.
- ប្រកាសលេខ ៤៣៨ អបស.អធម ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យបើកវគ្គបណ្តុះបណ្តាលបរិញ្ញាបត្រគិលានុបដ្ឋាកបែបពាក់កណ្តាលពេល។

ស.អ. ជាមជ្ឈមណ្ឌលសិក្សាអប់រំដ៏ធំមួយ នៅក្នុងខេត្តសៀមរាបដែលមានទំហំផ្ទៃដី ១៥ ពាន់ម៉ែត្រការ៉េ ក្នុងនោះរួមមាន អគារសិក្សាស្រាវជ្រាវនិងអនុវត្តន៍ ការិយាល័យការងារ បណ្ណាល័យ អន្តេវាសិកដ្ឋាន ចំណត-

យានជំនិះ តារាងកីឡា និងអាហារដ្ឋាន។ ក្រៅពីនេះ ស.អ. មានបណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ស្របតាមមុខជំនាញដូចមានបង្ហាញក្នុងតារាងទី២។

**តារាងទី០២៖ មុខជំនាញ និងកម្រិតបណ្ដុះបណ្ដាលតាមមហាវិទ្យាល័យ**

| ល.រ | មហាវិទ្យាល័យ Faculties | មុខជំនាញ Majors | ច្បាប់អនុញ្ញាត Licenses | កម្រិតបណ្ដុះបណ្ដាល Level of Education | | |
|---|---|---|---|---|---|---|
| | | | | បរិ.រង Ass | បរិ B.A | ជាន់ខ្ពស់ M.A |
| ១ | ម.ស.ស Public Health | គិលានុបដ្ឋាកបែប ពាក់កណ្ដាលពេល Nursing Bridging Entry | ប្រកាសលេខ ៤៣៨ អបស.អធម ០១ ធ្នូ ២០២០ Prakas No 438 ABS.ATM 01 Dec 2020 | x | √ | x |
| | | គិលានុបដ្ឋាក Nursing | ប្រកាសលេខ ២៦៥៦ អយក. ប្រក ២១ តុលា ២០១៥ Prakas No 2656 AYK.BrK 21 Oct 2015 | √ | x | x |
| | | ឆ្មប Midwifery | | | | |
| ២ | ម.គ.ព.ទ Business Administration and Tourism | គណនេយ្យ Accounting | លិខិតលេខ ១៧៩៨ អយក.ឌស ៥ កក្កដា ២០០៥ Letter No 1798 AYK.DS 5 July 2005 | √ | √ | √ |
| | | ធនាគារ និងហិរញ្ញវត្ថុ Finance and Baking | | √ | √ | √ |
| | | ទីផ្សារ Marketing | | √ | √ | √ |
| | | គ្រប់គ្រងពាណិជ្ជកម្ម Business Management | | √ | √ | √ |
| | | កុំព្យូទ័រពាណិជ្ជកម្ម Business Computer | | √ | √ | √ |
| | | គ្រប់គ្រងធនធានមនុស្ស Human Resource Management | | √ | √ | √ |
| | | គ្រប់គ្រងប្រព័ន្ធព័ត៌មាន Information System Management | | √ | √ | √ |
| | | គ្រប់គ្រងសណ្ឋាគារ និង ទេសចរណ៍ Hotel and Tourism Management | | √ | √ | √ |

| ល.រ | មហាវិទ្យាល័យ<br>Faculties | មុខជំនាញ<br>Majors | ច្បាប់អនុញ្ញាត<br>Licenses | កម្រិតបណ្ដុះបណ្ដាល<br>Level of Education | | |
|---|---|---|---|---|---|---|
| | | | | បរិ.រង<br>Ass | បរិ<br>B.A | ជាន់ខ្ពស់<br>M.A |
| | | គ្រប់គ្រងពាណិជ្ជកម្ម បង្រៀនជាភាសាអង់គ្លេស និងកូរ៉េ<br>Business Management in English and Korean Languages | ប្រកាសលេខ ២៦៥៦ អយក. ប្រក ២១ តុលា ២០១៥<br>Prakas No 2656 AYK.BrK 21 Oct 2015 | √ | √ | |
| ៣ | ម.ម.ភ<br>Humanities and Foreign Languages | ភាសាអង់គ្លេស<br>English Language | លិខិតលេខ ១៧៩៨ អយក.ឧស ៥ កក្កដា ២០០៤<br>Letter No 1798 AYK.DS 5 July 2005 | √ | √ | |
| | | ភាសាកូរ៉េ<br>Korean Language | ប្រកាសលេខ ២៦៥៦ អយក. ប្រក ២១ តុលា ២០១៥<br>Prakas No 2656 AYK.BrK 21 Oct 2015 | √ | √ | |
| ៤ | ម.វ.ប<br>Science and Technology | វិទ្យាសាស្ត្រកុំព្យូទ័រ<br>Computer Science | លិខិតលេខ ១៧៩៨ អយក.ឧស ៥ កក្កដា ២០០៤<br>Letter No 1798 AYK.DS 5 July 2005 | | √ | √ |
| | | ព័ត៌មានវិទ្យា<br>Information Technology | | | √ | √ |
| ៥ | ម.ស.ន<br>Sociology and Law | នីតិសាធារណៈ<br>Public Law | លិខិតលេខ ១៧៩៨ អយក.ឧស ៥ កក្កដា ២០០៤<br>Letter No 1798 AYK.DS 5 July 2005 | | √ | √ |
| | | នីតិឯកជន<br>Private Law | | | √ | √ |
| | | សេដ្ឋកិច្ច<br>Economics | | | √ | √ |
| | | វិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ<br>Political Science and International Relations | | | √ | √ |
| ៦ | ម.ក.សិ<br>Agriculture | ក្សេត្រសាស្ត្រ<br>Agronomy | លិខិតលេខ ១៧៩៨ | √ | √ | |

| ល.រ | មហាវិទ្យាល័យ<br>Faculties | មុខជំនាញ<br>Majors | ច្បាប់អនុញ្ញាត<br>Licenses | កម្រិតបណ្ដុះបណ្ដាល<br>Level of Education | | |
|---|---|---|---|---|---|---|
| | | | | បរិ.រង<br>Ass | បរិ<br>B.A | ជាន់ខ្ពស់<br>M.A |
| | | អភិវឌ្ឍន៍ជនបទ<br>Rural Development | អយក.ឧស<br>៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | √ | √ | |
| ៧ | ម.វ.ស<br>Engineering and Architecture | សំណង់ស៊ីវិល<br>Civil Engineering | ប្រកាសលេខ<br>១៧៦៧ អយក.ប្រ<br>៨ វិច្ឆិកា ២០១៩<br>Prakas No 1767<br>AYK.BrK<br>08 August 2019 | | √ | |
| | | អគ្គិសនី និងអេឡិចត្រូនិច<br>Electricity and Electronics | | | √ | |
| | | ស្ថាបត្យកម្ម<br>Architecture | | | √ | |
| | | រចនាផ្ទៃកខាងក្នុង<br>Interior Design | | | √ | |

ស.អ. បានផ្ដល់ឱកាសឱ្យគណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតដើម្បីចូលរួមសកម្មភាពជាច្រើនដូចជា៖ ការចុះសហគមន៍ ការបោះជំរំ សិក្ខាសាលាជាតិនិងអន្តរជាតិ ការសិក្សាថ្នាក់អប់រំរដូវក្ដៅនៅសាកលវិទ្យាល័យដៃគូបរទេស(តៃវ៉ាន និងថៃ) កម្មវិធីផ្លាស់ប្តូរវប្បធម៌(សហរដ្ឋអាមេរិក ជប៉ុន កូរ៉េខាងត្បូង និងឥណ្ឌូនេស៊ី) និង កម្មសិក្សាជាតិនិងអន្តរជាតិ (ជប៉ុន)។

## ជំពូក ២
## ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តសញ្ញាណឡូហ្គោ

ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅរបស់ ស.អ. ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៨-២០២៣ និងដោយយោងតាមកំណត់ហេតុអង្គប្រជុំ លេខ ០២០១-១/២០ ស.អ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ស្ដីពីការកែសម្រួល ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅ ដូចខាងក្រោម៖

### ១.១. ចក្ខុវិស័យ

ស.អ. នឹងក្លាយជាគ្រឹះស្ថានអប់រំដែលបង្កើតកម្លាំងពលកម្មអាជីព សម្រាប់តម្រូវការទីផ្សារការងារកម្ពុជា និងអាស៊ានប្រកបដោយភាពជាអ្នកដឹកនាំ ភាពច្នៃប្រឌិត និងនវានុវត្តន៍ ស្របតាមបរិបទសាកលភាវូបនីយកម្ម។

### ១.២. បេសកកម្ម

ដើម្បីសម្រេចបានតាមចក្ខុវិស័យដែលបានកំណត់សាកលវិទ្យាល័យបានដាក់ចេញនូវបេសកកម្មចំនួន ០៣ ចំណុចដូចខាងក្រោម៖

- បណ្ដុះបណ្ដាលជំនាញផ្សេងៗ ស្របតាមតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ
- ផលិតធនធានមនុស្សប្រកបដោយគុណភាព និងឧត្តមភាព
- ផ្ដល់បរិយាកាសនៃការអប់រំ ការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍពេញមួយជីវិត។

### ១.៣. តម្លៃស្នូល

ការធានានូវគុណភាពត្រូវកើតចេញពីឆន្ទៈ កិច្ចខិតខំប្រឹងប្រែង និងចក្ខុវិស័យវែងឆ្ងាយដើម្បីជាមូលដ្ឋានក្នុងការធ្វើឱ្យសម្រេចបាននូវគុណភាព និងភាពជាអ្នកដឹកនាំ ដូចនេះសាកលវិទ្យាល័យដាក់ចេញនូវគុណតម្លៃដូចខាងក្រោម៖

**ក. គុណភាព**/Quality

- សុច្ចរិតភាព/Integrity
  - ភាពជឿជាក់/Reliability
  - ភាពស្មោះត្រង់/Honesty
  - ភាពទទួលខុសត្រូវ/Responsibility
- នវានុវត្តន៍/Innovation
  - ការគិតដោយភាពច្នៃប្រឌិត/Creative Thinking
  - ការបង្កើតឱកាស/Opportunity Creation
  - និរន្តរភាព/Sustainability
- ការចូលរួមសកម្មភាពសង្គម/Social Engagement
  - គណនេយ្យភាព/Accountability
  - ការប្ដេជ្ញាចិត្ត/Commitment
  - ការស្ម័គ្រចិត្ត/Volunteering

**ខ. ពុទ្ធិ**/Knowledge

- ភាពរីកចម្រើន និងការអភិវឌ្ឍ/Growth and Development
- ការទំនាក់ទំនងល្អក្នុងគ្រួសារ និងសង្គម/Good Relationship in family and Society
- សុខភាព សុវត្ថិភាព និងគុណភាពជីវិត/Health, Safety, and Quality of life

**គ. សីលធម៌**/Morality

- ភាពចុះសម្រុងគ្នា/Harmony
- ភាពថ្លៃថ្នូរក្នុងសង្គម/Dignity in society
- ស្មារតី និងមនសិការស្នេហាជាតិ/National Conscience and Spirit

## ១.៤. អត្តន័យឡូហ្គោ

អត្តន័យឡូហ្គោរបស់ ស.អ. ត្រូវបានកំណត់ស្របតាមកំណត់ហេតុអង្គប្រជុំលេខ ០២២០/១៧ ស.អ. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការអនុម័ត អត្តន័យឡូហ្គោ ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅនៃ ស.អ. ដូចតទៅ៖

- រូបអង្គរវត្ត៖ តំណាងឱ្យប្រភពចំណេះដឹងដែលមិនអាចកាត់ថ្លៃបាន
- ផ្លូវចូលទៅកាន់ប្រាសាទអង្គរវត្ត៖ សំដៅដល់មាគ៌ាឆ្ពោះទៅរកប្រភពនៃចំណេះដឹង
- រូបក្បាលនាគពណ៌បៃតងខ្ចី៖ តំណាងឱ្យចំណេះដឹងដែលផ្តល់ឱ្យភាពជោគជ័យ សម្បូរុងរឿង ត្រជាក់ត្រជុំ និងសុខដុមរមនា
- ផ្ទៃមេឃមានពពកសតិចៗ៖ តំណាងឱ្យចំណេះដឹងដែលប្រកបដោយភាពជាអ្នកដឹកនាំ គ្រប់កាលៈទេសៈ
- អក្សរ ស.អ. ជាភាសាជាតិពណ៌ខៀវ៖ តំណាងឱ្យតម្លៃនៃកម្មវិធីថ្នាក់ជាតិ
- អក្សរ ស.អ. ជាភាសាអង់គ្លេសពណ៌ខៀវ៖ តំណាងឱ្យការត្រៀមខ្លួនជានិច្ច របស់ ស.អ. ក្នុងការធ្វើសមាហរណកម្មទៅក្នុងសកលលោក
- រង្វង់មូលព័ទ្ធជុំវិញផ្នែកខាងក្នុង៖ តំណាងឱ្យសាមគ្គីភាពរវាងនិស្សិតកំពុងសិក្សា និងអតីតនិស្សិត ស.អ.
- រង្វង់មូលព័ទ្ធជុំវិញផ្នែកខាងក្រៅ៖ តំណាងឱ្យការត្រៀមខ្លួនប្រកួតប្រជែង របស់និស្សិត ស.អ. នៅក្នុងទីផ្សារការងារជាតិ និងអន្តរជាតិ
- ផ្ទៃពណ៌សនៅចន្លោះរង្វង់មូលព័ទ្ធខាងក្នុង និងខាងក្រៅ៖ តំណាងឱ្យតម្លៃ នៃការលះបង់ ស្មោះស្ម័គ្រ និងសេចក្តីស្រឡាញ់របស់និស្សិត ស.អ. ក្នុងការបម្រើការងារតាមផ្នែកនីមួយៗ ស្របតាមជំនាញរបស់ខ្លួននៅគ្រប់កម្រិត និងគ្រប់បរិបទ។

## ជំពូក ៣
## គោលដៅយុទ្ធសាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ

### ៣.១. គោលដៅយុទ្ធសាស្ត្រ

សម្រាប់ឆ្នាំ ២០២០-២០២១ ការបន្តការរៀបចំ និងអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ ថែមទាំងកំណត់យន្តការ ធានាគុណភាពអប់រំកម្រិតជាតិ ដើម្បីធានាសមត្ថភាពអ្នកសិក្សា និងអ្នកស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ កម្ពុជា និងតំបន់ ជាពិសេសខេត្តសៀមរាប ស.អ. នឹងបន្តដំណើរការអនុវត្តគោលដៅយុទ្ធសាស្ត្រដូចខាងក្រោម៖

- ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ
- ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព
- ការស្រាវជ្រាវ និងការអភិវឌ្ឍ
- ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ។

### ៣.២. ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រខាងលើ ស.អ. បានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ៖

៣.២.១- ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- អភិវឌ្ឍរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ ការិយាល័យ និងអង្គភាពចំណុះ
- កែសម្រួលបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាភិបាល
- បន្សុីលទ្ធផលអនុវត្តការងារជាមួយចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្ថន័យរបស់ឡូហ្គោ ដែលបានកំណត់

៣.២.២- ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ធ្វើសង្គតិភាពគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍បុគ្គលិករដ្ឋបាលទៅនឹងតួនាទីភារកិច្ចរបស់ខ្លួន
- កែលម្អគោលការណ៍លើកទឹកចិត្តបុគ្គលិក

៣.២.៣- ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំផែនការប្រចាំខែ និងត្រីមាស
- រៀបចំរបាយការណ៍ប្រចាំខែ និងត្រីមាស

៣.២.៤- ការកំណត់ប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្រ្តខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អបុគ្គលិកគ្រប់ជាន់ថ្នាក់ ប្រចាំត្រីមាស
- វាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅប្រចាំខែ ត្រីមាស និងឆ្នាំ

៣.២.៥- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្រ្តខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើសង្គតិភាពប្រព័ន្ធគណនេយ្យ ស.អ. ទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ស្របតាមគោលការណ៍គណនេយ្យ ស.អ.

៣.២.៦- ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្រ្តខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កែសម្រួលកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សា
- កែសម្រួលកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះ-បណ្តាល
- ចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត
- ស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល
- អភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- ស្រាវជ្រាវសៀវភៅយោងបន្ថែម តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- ប្រជុំផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាល

៣.២.៧- ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្រ្តខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ និងកែលម្អបទបញ្ជាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យ
- ធ្វើការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ.
- លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ
- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន

៣.២.៨- ការអភិវឌ្ឍសម្ភារបរិក្ខារូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ
- ពិនិត្យ វាយតម្លៃសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ
- បង្កើននិងអភិវឌ្ឍសំណង់អគារព្រមទាំងសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ

៣.២.៩- ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងតម្រង់ទិសអំពីបទបញ្ជាផ្ទៃក្នុងនិស្សិត
- រៀបចំសន្និសីទ សិក្ខាសាលា និងបាឋកថា
- ជំរុញនិស្សិតចូលរួមកម្មវិធីសហគមន៍ ធ្វើកម្មសិក្សា និងសកម្មភាពសង្គមផ្សេងៗ

៣.២.១០- ការបង្កើនគុណភាពផ្តល់សេវាកម្មនិស្សិត

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ប្រឹក្សានិស្សិត គ្រប់កម្រិត
- ពង្រឹងវិន័យ និងក្រមសីលធម៌និស្សិតគ្រប់កម្រិត
- លើកទឹកចិត្តនិស្សិតគ្រប់កម្រិត
- កែសម្រួលក្លឹបនិស្សិតស្ម័គ្រចិត្ត អតីតនិស្សិត និងក្លឹបផ្សេងៗ
- រៀបចំកម្មវិធី ព្រឹត្តិការណ៍ ទស្សនកិច្ចសិក្សា
- រៀបចំស្ទង់មតិអំពីភាពមានការងារធ្វើនិស្សិត និងអតីតនិស្សិត

៣.២.១១- ការរៀបចំការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កែលម្អគោលការណ៍ និងនីតិវិធីស្រាវជ្រាវរបស់ ស.អ.
- ទាក់ទាញគម្រោងស្រាវជ្រាវពីស្ថាប័ននានា
- ពិនិត្យ និងកែសម្រួលលក្ខន្តិកៈមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីឧត្តមភាព និងនវានុវត្តន៍

៣.២.១២- ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណាននិស្សិត

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើតកម្មវិធីប្រកួតប្រជែង

៣.២.១៣- ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- លើកទឹកចិត្តបុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យឱ្យស្រាវជ្រាវ
- ផ្សព្វផ្សាយស្នាដៃរបស់អ្នកស្រាវជ្រាវ

៣.២.១៤- ការធ្វើទំនើបកម្ម និងនវានុវត្តឯកសារសម្រាប់ស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ និងកែលម្អគោលការណ៍ការបណ្ដុះបណ្ដាលពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក
- ពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់បណ្ណាល័យទូរនិម្មិត
- បំប្លែងឯកសារទៅជាឌីជីថល

៣.២.១៥- ការបោះពុម្ព និងផ្សព្វផ្សាយ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ចងក្រង៖
  - ផែនការប្រចាំឆ្នាំ
  - សៀវភៅកត់ត្រា ដែលរំលេចព័ត៌មានសង្ខេបតាមមុខជំនាញ
  - ខិតប័ណ្ណ និងបដាព័ត៌មានសិក្សា
  - វីដេអូឃ្លីប អំពីសកម្មភាពនានារបស់ ស.អ.
  - សៀវភៅកម្មវិធីសិក្សា
  - របាយការណ៍ស្ទង់មតិនានា
  - និទ្ទេសបទស្ទ័យវាយតម្លៃ សម្រាប់ គ.ទ.ក និង ឧស.
  - របាយការណ៍ស្ដីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ
  - គោលការណ៍ និងនីតិវិធីនានារបស់ ស.អ.
- បោះពុម្ព និងផ្សព្វផ្សាយ៖
  - សៀវភៅសិក្សាគោលតាមមុខជំនាញ
  - អាវយឺត ឡូហ្គោ នាមប័ណ្ណ និង កាតសម្គាល់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិត
  - ផែនការប្រចាំឆ្នាំ
  - សៀវភៅកត់ត្រា ដែលរំលេចព័ត៌មានសង្ខេបតាមមុខជំនាញ
  - ខិតប័ណ្ណ និងបដាព័ត៌មានសិក្សា
  - វីដេអូឃ្លីប អំពីសកម្មភាពនានារបស់ ស.អ.
  - សៀវភៅកម្មវិធីសិក្សា

- ○ របាយការណ៍ស្ទង់មតិនានា
- ○ និទ្ទេសបទស្ទ័យវាយតម្លៃ សម្រាប់ គ.ទ.ក និង ឧស.
- ○ របាយការណ៍ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ
- ○ គោលការណ៍ និងនីតិវិធីនានារបស់ ស.អ.

៣.២.១៦- ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បន្តអនុវត្ត និងធ្វើអនុស្សរណៈយោគយល់គ្នាជាមួយដៃគូជាតិ និងអន្តរជាតិថ្មីបន្ថែម

៣.២.១៧- ការផ្លាស់ប្តូរវប្បធម៌

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ជំរុញបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតគ្រប់កម្រិតធ្វើទស្សនកិច្ចសិក្សា ចូលរួមវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា នៅក្នុងប្រទេស និងបរទេស
- ទទួលបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតគ្រប់កម្រិតពីដៃគូជាតិ និងអន្តរជាតិ ធ្វើទស្សនកិច្ចសិក្សា ចូលរួមវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា នៅ ស.អ.

៣.២.១៨- ការផ្តល់អាហាររូបករណ៍

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កែលម្អគោលការណ៍ស្តីពីការផ្តល់អាហារូបករណ៍
- ស្វែងរកមូលនិធិសម្រាប់គាំទ្រដល់ការផ្តល់អាហារូបករណ៍

៣.២.១៩- ការស្រាវជ្រាវរួមគ្នា

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ និងកែលម្អគោលការណ៍ស្រាវជ្រាវ
- បោះពុម្ពគម្រោងស្រាវជ្រាវ
- ស្វែងរកមូលនិធិសម្រាប់គាំទ្រដល់ការស្រាវជ្រាវ

៣.២.២០- ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ និងកែសម្រួលគោលការណ៍ធានាគុណភាពអប់រំផ្ទៃក្នុងរបស់ ស.អ.

៣.២.២១- ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- អនុវត្ត តាមដាន និងវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង
- រៀបចំនិទ្ទេសបទស្វ័យវាយតម្លៃ

៣.២.២២- ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ/អន្តរជាតិ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បន្តអនុវត្តស្តង់ដារបស់ គ.ទ.ក ដើម្បីត្រៀមខ្លួនវាយតម្លៃ
- រៀបចំគោលការណ៍នានាដើម្បីត្រៀមខ្លួនវាយតម្លៃគុណភាពអប់រំស្របតាមស្តង់ដា ISO ។

## ជំពូក ៤
## លទ្ធផលរំពឹងទុក និងសកម្មភាពចម្បង

### ៤.១. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់

#### ៤.១.១- អភិវឌ្ឍរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ ការិយាល័យ និងអង្គភាពចំណុះ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានរចនាសម្ព័ន្ធដឹកនាំ និងលំហូរការងារច្បាស់លាស់នៅតាមការិយាល័យ និងអង្គភាពចំណុះដើម្បីផ្សព្វផ្សាយ និងអនុវត្តប្រកបដោយប្រសិទ្ធភាព ៧០% នៃផែនការយុទ្ធសាស្ត្រ ០៥ឆ្នាំ
- មានដំណើរការ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធដឹកនាំ
- កំណត់លំហូរការងារនៅតាមការិយាល័យ និងអង្គភាពចំណុះ
- កែសម្រួលឧបករណ៍សម្រាប់វាស់ប្រសិទ្ធភាពការងាររបស់បុគ្គលិកគ្រប់កម្រិត។

#### ៤.១.២-កែសម្រួលបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាភិបាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានបទបញ្ញាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានកែលម្អ
- មានលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់វាយតម្លៃក្រុមប្រឹក្សាភិបាល
- មានការផ្សព្វផ្សាយច្បាស់លាស់អំពីបទបញ្ញាផ្ទៃក្នុង និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាលស្របតាមមធ្យោបាយទាំងអស់របស់ ស.អ.

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការពិនិត្យ និងកែលម្អបទបញ្ញាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំ និងផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមប្រឹក្សាភិបាល
- រៀបចំ និងផ្សព្វផ្សាយលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមប្រឹក្សាភិបាល
- រៀបចំផែនការស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាល
- វាយតម្លៃ និងរៀបចំលទ្ធផលស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាល

- ចងក្រង និងបោះពុម្ពលទ្ធផលស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុង និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាល។

### ៤.១.៣- បន្សុីលទ្ធផលអនុវត្តការងារជាមួយចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និង អត្តសញ្ញាណរបស់ឡូហ្គោ ដែលបានកំណត់

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានតារាងលទ្ធផលការងារដែលបានបន្សុីជាមួយនឹងចក្ខុវិស័យ
- មានតារាងលទ្ធផលការងារដែលបានបន្សុីជាមួយនឹងបេសកកម្ម
- មានតារាងលទ្ធផលការងារដែលបានបន្សុីជាមួយនឹងតម្លៃស្នូល
- មានតារាងលទ្ធផលការងារដែលបានបន្សុីជាមួយនឹងអត្តន័យរបស់ឡូហ្គោ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- ធ្វើផែនការរៀបចំតារាងប្រៀបធៀបលទ្ធផលការងារជាមួយនឹងចក្ខុវិស័យ
- រៀបចំតារាងប្រៀបធៀបលទ្ធផលការងារជាមួយនឹងចក្ខុវិស័យ
- ផ្សព្វផ្សាយលទ្ធផលការងារដែលបានបន្សុីជាមួយនឹងចក្ខុវិស័យដល់អ្នកពាក់ព័ន្ធ
- ធ្វើផែនការរៀបចំតារាងប្រៀបធៀបលទ្ធផលការងារជាមួយនឹងបេសកកម្ម
- រៀបចំតារាងប្រៀបធៀប និងផ្សព្វផ្សាយលទ្ធផលការងារជាមួយនឹងបេសកកម្ម
- ធ្វើផែនការរៀបចំតារាងប្រៀបធៀបលទ្ធផលការងារជាមួយនឹងតម្លៃស្នូល
- រៀបចំតារាងប្រៀបធៀប និងផ្សព្វផ្សាយលទ្ធផលការងារជាមួយនឹងតម្លៃស្នូល
- ធ្វើផែនការរៀបចំតារាងប្រៀបធៀបលទ្ធផលការងារជាមួយនឹងអត្តន័យរបស់ឡូហ្គោ
- រៀបចំតារាងប្រៀបធៀប និងផ្សព្វផ្សាយលទ្ធផលការងារជាមួយនឹងអត្តន័យរបស់ឡូហ្គោ

## ៤.២. ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត

### ៤.២.១. ធ្វើសវនកម្មគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍បុគ្គលិករដ្ឋបាលទៅនឹង តួនាទីភារកិច្ចរបស់ខ្លួន

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានបញ្ជីបច្ចុប្បន្នភាពបុគ្គលិករដ្ឋបាលគ្រប់កម្រិតដែលរំលេចអំពីគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍
- ទទួលបានបុគ្គលិករដ្ឋបាលគ្រប់កម្រិតចំនួនយ៉ាងតិច ៨០% មានគុណវុឌ្ឍិ សមត្ថភាព និងបទពិសោធន៍ឆ្លើយតបទៅនឹងការងាររបស់ខ្លួន

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- ធ្វើផែនការរៀបចំបញ្ជីបច្ចុប្បន្នភាពបុគ្គលិករដ្ឋបាលគ្រប់កម្រិត

- រៀបចំ និងផ្សព្វផ្សាយបញ្ជីបច្ចុប្បន្នភាពបុគ្គលិករដ្ឋបាលគ្រប់កម្រិត
- ធ្វើផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាល
- ស្ទង់មតិ និងផ្សព្វផ្សាយលទ្ធផលពីការពេញចិត្តលើការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាល

## ៤.៣. ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់

### ៤.៣.១- កែលម្អគោលការណ៍លើកទឹកចិត្តបុគ្គលិក

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានគោលការណ៍លើកទឹកចិត្តបុគ្គលិកច្បាស់លាស់
- មានបុគ្គលិកទទួលបានការលើកទឹកចិត្តស្របតាមគោលការណ៍លើកទឹកចិត្តបុគ្គលិក

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- ធ្វើផែនការកែលម្អគោលការណ៍លើកទឹកចិត្តបុគ្គលិក
- រៀបចំ និងផ្សព្វផ្សាយគោលការណ៍លើកទឹកចិត្តបុគ្គលិក
- វាយតម្លៃការងារនិងលើកទឹកចិត្តបុគ្គលិក។

### ៤.៣.២- រៀបចំផែនការប្រចាំខែ និងត្រីមាស

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការប្រចាំខែ និងត្រីមាស ដែលរំលេចចេញនូវសកម្មភាពការងារ និងហិរញ្ញវត្ថុច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយ និងធ្វើការស្ទង់មតិអំពីប្រសិទ្ធភាពនៃការរៀបចំផែនការច្បាស់លាស់

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- បង្កើត អនុវត្ត និងផ្សព្វផ្សាយផែនការប្រចាំខែ និងត្រីមាស

### ៤.៣.៣- រៀបចំរបាយការណ៍ប្រចាំខែ និងត្រីមាស

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានរបាយការណ៍លទ្ធផលការងារប្រចាំខែ និងត្រីមាស ដែលរំលេចនូវការប្រៀបធៀបរវាងផែនការ និងការអនុវត្តការងារច្បាស់លាស់
- មានការផ្សព្វផ្សាយ និងធ្វើការស្ទង់មតិអំពីប្រសិទ្ធភាពនៃការរៀបចំរបាយការណ៍ច្បាស់លាស់

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ប្រចាំខែ និងត្រីមាស

- ធ្វើផែនការស្ទង់មតិអំពីប្រសិទ្ធភាពនៃការរៀបចំរបាយការណ៍
- ធ្វើការស្ទង់មតិ និងផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃការរៀបចំរបាយការណ៍។

## ៤.៤. ការកំណត់ប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់

### ៤.៤.១- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អបុគ្គលិកគ្រប់ជាន់ថ្នាក់ ប្រចាំត្រីមាស

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អបុគ្គលិកច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការពេញចិត្តពីបុគ្គលិកគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តការងារយ៉ាងតិចចំនួន៩៥%

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អបុគ្គលិក
- រៀបចំផែនការ និងស្ទង់មតិពីភាពពេញចិត្តពីរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តការងារ។

### ៤.៤.២- វាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅប្រចាំខែ ត្រីមាស និងឆ្នាំ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តការងារច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការអនុវត្តការងារស្របតាមផែនការ និងទិសដៅដែលបានកំណត់

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តការងារ
- ធ្វើការប្រៀបធៀបលទ្ធផលការងាររវាងផែនការ និងទិសដៅដែលបានកំណត់ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។

## ៤.៥. ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

### ៤.៥.១- រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងដល់គណៈគ្រប់គ្រង

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។

### ៤.៥.២- ធ្វើសង្គតិភាពប្រព័ន្ធគណនេយ្យ ស.អ. ទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានប្រព័ន្ធគណនេយ្យដែលស្របទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា
- មានប្រព័ន្ធគណនេយ្យដែលទទួលស្គាល់ពីដៃគូពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការធ្វើសង្គតិភាពប្រព័ន្ធគណនេយ្យ ស.អ. ទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។

### ៤.៥.៣- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
- មានការផ្សព្វផ្សាយ និងធ្វើការស្ទង់មតិអំពីប្រសិទ្ធភាពការប្រើប្រាស់ថវិកាសម្រាប់ការគ្រប់គ្រងច្បាស់លាស់

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
- ធ្វើផែនការ និងស្ទង់មតិអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង។

### ៤.៥.៤- ធ្វើសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ស្របតាមគោលការណ៍គណនេយ្យ ស.អ.

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ស្របតាមគោលការណ៍គណនេយ្យ ស.អ. ដែលមានតម្លាភាព
- មានការផ្សព្វផ្សាយរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ស្របតាមគោលការណ៍គណនេយ្យ ស.អ. ដែលមានតម្លាភាព។

## ៤.៦. ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ

### ៤.៦.១- កែសម្រួលកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សា

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការរៀបចំការកែសម្រួលកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សាច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សាដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការកែសម្រួលកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សា
- ស្ទង់មតិ និងផ្សព្វផ្សាយពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត តាមគំរូថ្មីរបស់ឧត្តមសិក្សា។

### ៤.៦.២-កែសម្រួលកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះ-បណ្តាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការរៀបចំការកែសម្រួលកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះបណ្តាលច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយកម្មវិធីកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការកែសម្រួលកម្មវិធីកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះបណ្តាល
- កែសម្រួល និងផ្សព្វផ្សាយកម្មវិធីកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា ស្របតាមមុខជំនាញកំពុងបណ្តុះបណ្តាល ដល់អ្នកពាក់ព័ន្ធ។

### ៤.៦.៣- ចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិតច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- ការផ្សព្វផ្សាយសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិតដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំ និងផ្សព្វផ្សាយផែនការចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត
- បោះពុម្ព និងផ្សព្វផ្សាយសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិតដល់អ្នកពាក់ព័ន្ធ។

### ៤.៦.៤- ស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាលច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយលទ្ធផលស្ទង់មតិអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។

### ៤.៦.៥- អភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការអភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាលច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានសៀវភៅគោលចំនួន ៥០% នៃមុខជំនាញនីមួយៗដែលកំពុងបណ្តុះបណ្តាលត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការអភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- បោះពុម្ព និងផ្សព្វផ្សាយសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ។

### ៤.៦.៦- ស្រាវជ្រាវសៀវភៅយោងបន្ថែម តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការអភិវឌ្ឍសៀវភៅយោង សម្រាប់ស្រាវជ្រាវ និងតម្កល់នៅក្នុងបណ្ណាល័យ និងបណ្ណាល័យទូរនិម្មិត តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាលច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានសៀវភៅយោងចំនួន ៥ ច្បាប់នៃមុខវិជ្ជានីមួយៗ ដែលកំពុងបណ្តុះបណ្តាលត្រូវបានតម្កល់នៅក្នុងបណ្ណាល័យ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការអភិវឌ្ឍសៀវភៅយោង សម្រាប់ស្រាវជ្រាវដែលតម្កល់ទុកនៅក្នុងបណ្ណាល័យតាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- រៀបចំផែនការបង្កើតបណ្ណាល័យទូរនិម្មិតសម្រាប់ស្រាវជ្រាវ តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- រៀបចំផែនការបោះពុម្ពសៀវភៅយោងបន្ថែម សម្រាប់ស្រាវជ្រាវ និងតម្កល់ទុកនៅក្នុងបណ្ណាល័យ តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល។

### ៤.៦.៧- ស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានរបាយការណ៍ស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការ និងស្ទង់មតិពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាល។

## ៤.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ

### ៤.៧.១- ពិនិត្យ និងកែលម្អបទបញ្ជាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការពិនិត្យ និងកែលម្អបទបញ្ជាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យច្បាស់លាស់ស្របតាមគំរូរបស់ ស.អ.

- មានការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យដល់អ្នកពាក់ព័ន្ធយ៉ាងតិច ៨០%
- មានការផ្សព្វផ្សាយលទ្ធផលស្ទង់មតិអំពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យដល់អ្នកពាក់ព័ន្ធយ៉ាងតិច ៨០%

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅៈ

- រៀបចំផែនការពិនិត្យ និងកែលម្អបទបញ្ញាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ
- ស្ទង់មតិ និងផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងគ្រូបង្រៀន/សាស្ត្រាចារ្យ។

### ៤.៧.២.- ធ្វើការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ.

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹងៈ

- មានផែនការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- លទ្ធផលស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ. ត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធយ៉ាងតិច ៨០%

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅៈ

- រៀបចំផែនការ និងស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ. ។

### ៤.៧.៣-លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹងៈ

- មានគោលការណ៍លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យច្បាស់លាស់
- មានគ្រូបង្រៀន/សាស្ត្រាចារ្យចំនួន ៥០% ទទួលបានការលើកទឹកចិត្តស្របតាមគោលការណ៍លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅៈ

- រៀបចំផែនការ និងកែលម្អ គោលការណ៍លើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ
- ធ្វើការវាយតម្លៃ និងលើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ។

### ៤.៧.៤- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹងៈ

- មានផែនការរៀបចំសិក្ខាសាលាស្ដីពីវិធីសាស្ត្របង្រៀនច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានគ្រូបង្រៀន/សាស្ត្រាចារ្យចំនួន ៨៥% បានចូលរួម
- មានការផ្សព្វផ្សាយលទ្ធផលស្ទង់មតិស្ដីពីប្រសិទ្ធភាពនៃការរៀបចំសិក្ខាសាលាស្ដីពីវិធីសាស្ត្របង្រៀន

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- ធ្វើផែនការ និងរៀបចំសិក្ខាសាលាស្ដីពីវិធីសាស្ត្របង្រៀន។

## ៤.៨.ការអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ

### ៤.៨.១- ពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានការផ្សព្វផ្សាយគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវដល់អ្នកពាក់ព័ន្ធយ៉ាងតិច ៨០%
- មានការផ្សព្វផ្សាយលទ្ធផលស្ទង់មតិអំពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវដល់អ្នកពាក់ព័ន្ធយ៉ាងតិច ៨០%

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- ធ្វើផែនការពិនិត្យ និងកែលម្អគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវ
- ស្ទង់មតិ និងផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយគោលការណ៍ប្រើប្រាស់សម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវ។

### ៤.៨.២-ពិនិត្យ វាយតម្លៃ និងអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវ

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានផែនការពិនិត្យ វាយតម្លៃ និងអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវច្បាស់លាស់ ស្របតាមគំរូរបស់ ស.អ.
- មានសម្ភាររូបវន្តសម្រាប់ការសិក្សា និងការស្រាវជ្រាវគ្រប់គ្រាន់ និងមានគុណភាព

